មេរៀនទី១

# របៀបដែលអ្នកអាចរកឃើញនូវអ្វីដែលព្រះទ្រង់តម្រូវ

***តើអ្វីជាពត៌មានដ៏សំខាន់ដែលមាននៅក្នុងព្រះគម្ពីរ? (១)***
***តើអ្នកណាជាអ្នកនិពន្ធព្រះគម្ពីរ? (២)***
***ហេតុអ្វីអ្នកគួររៀនសូត្រព្រះគម្ពីរ? (៣)***

១. ព្រះគម្ពីរជាអំណោយមួយដ៏មានតម្លៃពីព្រះ គឺប្រៀបដូចនឹងសំបុត្រពីបិតាមួយរូបដ៏ប្រកបដោយសេចក្ដីស្រឡាញ់សរសេរទៅឲ្យបុត្រាបុត្រីរបស់លោក ។ ព្រះគម្ពីរប្រាប់យើងនូវសេចក្ដីពិតអំពីព្រះ—ថាទ្រង់ជាអ្នកណា ហើយបមាណីយរបស់ទ្រង់ជាអ្វី ។ ព្រះគម្ពីរពន្យល់នូវរបៀបលៃលកដោះស្រាយបញ្ហានិងរបៀបរកសុភមង្គលពិតឃើញ ។ មានតែព្រះគម្ពីរទេដែលប្រាប់យើងនូវអ្វីៗដែលយើងត្រូវធ្វើដើម្បីផ្គាប់ព្រះហឫទ័យព្រះ ។—ទំនុកដំកើង ១:១-៣; អេសាយ ៤៨:១៧, ១៨

២. ព្រះគម្ពីរបានត្រូវសរសេរដោយបុរសប្រហែលជា៤០នាក់ ក្នុងរយ:ពេល១.៦០០ឆ្នាំ ចាប់ផ្ដើមក្នុងឆ្នាំ១៥១៣ ម.ស.យ. ។ ព្រះគម្ពីរគឺមានសៀវភៅតូចៗ៦៦ក្បាលបូកបញ្ចូលគ្នា ។ ឯពួកអ្នកសរសេរព្រះគម្ពីរ ត្រូវបានព្រះបណ្ដាលឲ្យគេតែងពាក្យចេញមក ។ ពួកគេសរសេរគំនិតរបស់ទ្រង់ មិនមែនរបស់ខ្លួនគេទេ ។ ដូច្នេះ ព្រះដែលគង់នៅក្នុងស្ថានសួគ៌ ជាអ្នកនិពន្ធព្រះគម្ពីរ មិនមែនមនុស្សមួយរូបណាលើផែនដីឡើយ ។—ធីម៉ូថេទី២ ៣:១៦, ១៧; ពេត្រុសទី២ ១:២០, ២១

៣. ព្រះទ្រង់បានយកព្រះទ័យទុកដាក់ចំពោះព្រះគម្ពីរ ដើម្បីឲ្យព្រះគម្ពីរបានត្រូវចម្លងដោយត្រឹមត្រូវនិងរក្សាការពារទុកផង ។ ព្រះគម្ពីរបានត្រូវបោះពុម្ពច្រើនជាងសៀវភៅឯណាទាំងអស់ ។ មិនមែនមនុស្សគ្រប់ៗរូបនឹងសប្បាយចិត្តនោះទេ ដោយឃើញអ្នករៀនសូត្រព្រះគម្ពីរ ប៉ុន្តែសូមកុំឲ្យការនេះឃាត់ឃាំងអ្នកឡើយ ។ អនាគតដ៏អស់កល្បរបស់អ្នកគឺស្រេចតែនឹងអ្នកទទួលស្គាល់ព្រះ ហើយធ្វើតាមព្រះហឫទ័យនៃទ្រង់ទោះបីមានការប្រឆាំងយ៉ាងណាក៏ដោយ ។—ម៉ាថាយ ៥:១០-១២; យ៉ូហាន ១៧:៣

